លេខ ១២ ខែ ធ្នូ ឆ្នាំ១៩៩០

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រឹត្យ-ច្បាប់
- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសម្រេច
- សារាចរ
- សារាចរណែនាំ

ផ្សាយចេញពីខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីជារៀងរាល់ខែ

Downloaded from http://www.khmerlaws.com

# មាតិកា

## I – ក្រុមប្រឹក្សារដ្ឋ

### ១ – ក្រឹត្យ


១១-១២-៩០ ក្រឹត្យលេខ ៨៨ ក្រ ស្តីពីការលើកលែងទោស អោយទណ្ឌិតនារី ឈ្មោះ កង សុខ ៣០៨

១១-១២-៩០ ក្រឹត្យលេខ ៨៩ ក្រ ស្តីពីការលើកលែងទោសអោយទណ្ឌិតចំនួន ៨ នាក់ ៣០៩


## II – ក្រុមប្រឹក្សារដ្ឋមន្ត្រី

### ១ – អនុក្រឹត្យ


០៨-១២-៩០ អនុក្រឹត្យលេខ ៣៤ អនក្រ ស្តីពីការរំសាយ បង្កើត និងប្តូរឈ្មោះ នាយកដ្ឋានមួយចំនួនចំណុះក្រសួងការបរទេស ៣១២


### ២ – សេចក្តីសំរេច


០៥-១២-៩០ សេចក្តីសំរេចលេខ ១៧៣ សសរ ស្តីពីការប្រើប្រាស់អត្តសញ្ញាណប័ណ្ណពលរដ្ឋ ជំនួសលិខិតធ្វើដំណើរ ៣១៤

២០-១២-៩០ សេចក្តីសំរេចលេខ ១៨០ សសរ ស្តីពីការគ្រប់គ្រងបេឡាថវិការដ្ឋ ពីធនាគារជាតិ មកក្រសួងហិរញ្ញវត្ថុ ៣១៥

២០-១២-៩០ សេចក្តីសំរេចលេខ ១៨១ សសរ ស្តីពីគោលការណ៍ស្តារលទ្ធភាពពលកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈ និងដោះស្រាយការងារជូនជនពិការ ៣១៧

២៥-១២-៩០ សេចក្តីសំរេចលេខ ១៨៤ សសរ ស្តីពីរបបសោធននិវត្តន៍ និងសោធនពាក់កណ្តាលសមត្ថភាពពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ៣២១


### ៣ – សេចក្តីណែនាំ


០៨-១២-៩០ សេចក្តីណែនាំលេខ ០៣ សណន ស្តីពីការកែសំរួលសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ៣២៧


### ៤ – សេចក្តីកំណត់


០៥-១២-៩០ សេចក្តីកំណត់លេខ ០១ សកណ ស្តីអំពីវិធានប្រឡងប្រណាំងស្នេហាជាតិការពារមាតុភូមិ ឆ្នាំ ១៩៩១ ១៩៩៥ ៣២៩


Downloaded from http://www.khmerlaws.com

# I – ក្រុមប្រឹក្សារដ្ឋ

## ក្រឹត្យ

## ក្រឹត្យលេខ ៧៧ ក្រ

## ក្រុមប្រឹក្សារដ្ឋ
## នៃរដ្ឋកម្ពុជា

– បានឃើញមាត្រា ៦០ ចំណុច ១១ នៃរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

បានឃើញច្បាប់ស្តីពីការរៀបចំរដ្ឋសភា និងក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ ស្តីអំពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញច្បាប់ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០២ ក្រ ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ១៩៨៨ ស្តីពីលក្ខណ្ឌសំរាប់លើកលែងទោស ឬ បន្ធូរទោសអោយទណ្ឌិត

ក្រោយពីបានពិនិត្យយោបល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង សំណុំរឿងរបស់ទណ្ឌិត ៨ រូប នៅខេត្តកំពង់ធំ

– យោងកំណត់ហេតុនៃសម័យប្រជុំសាមញ្ញក្រុមប្រឹក្សារដ្ឋ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៩០

### សំរេច

*មាត្រា ១* .– ត្រូវបានលើកលែងទោសអោយទណ្ឌិតនារីឈ្មោះ *កង សុខ* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ ដោយអំណាចសាលក្រម លេខ ១៦ ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ ១៩៨៩ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

*មាត្រា ២* .– ការលើកលែងទោសអោយទណ្ឌិតនារីឈ្មោះ *កង សុខ* នេះពុំមានឥទ្ធិភាពធ្វើអោយប៉ះពាល់ដល់ការសំរេចពីសំណងរដ្ឋប្បវេណីឡើយ ។

Downloaded from http://www.khmerlaws.com

*មាត្រា ៣* — ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ១៩៩០*

ជ. ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

# ក្រឹត្យលេខ ៧៨ ក្រ

## ក្រុមប្រឹក្សារដ្ឋ

## នៃរដ្ឋកម្ពុជា

— បានឃើញមាត្រា ៦០ ចំណុច ១១ នៃរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញច្បាប់ ស្តីពីការចាត់តាំងអង្គការតុលាការ និងអយ្យការដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០២ ក្រ ចុះថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីលក្ខណ្ឌ សំរាប់លើកលែងទោស ឬ បន្ធូរទោសអោយទណ្ឌិត

— ក្រោយពីបានពិនិត្យយោបល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង សំណុំរឿងរបស់ទណ្ឌិត ៨ រូប នៅខេត្តកំពង់ធំ

— យោងកំណត់ហេតុនៃសម័យប្រជុំសាមញ្ញក្រុមប្រឹក្សារដ្ឋ ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩០

— ដើម្បីឱបអរសាទរក្នុងឱកាសរំលឹកខួបលើកទី ១២ ទិវាបុណ្យជាតិ ៧ មករា ឆ្នាំ១៩៩១

Downloaded from http://www.khmerlaws.com

## សំរេច

*មាត្រា ១ .* — ត្រូវបានលើកលែងទោសអោយទណ្ឌិតចំនួន ៧ នាក់ ដែលបានខិតខំ
អប់រំកែប្រែខ្លួនល្អប្រសើរ ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១ — ទណ្ឌិតឈ្មោះ *ឆន ផន* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៨៦ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

២ — ទណ្ឌិតឈ្មោះ *គិន ឈើយ* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ ចុះថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៨៦ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

៣ — ទណ្ឌិតឈ្មោះ *ថក ធីន* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៨៩ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

៤ — ទណ្ឌិតឈ្មោះ *ស៊ុច រ៉េប* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៨៩ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

៥ — ទណ្ឌិតឈ្មោះ *ឯក ជ្រេន* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩០ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

៦ — ទណ្ឌិតឈ្មោះ *ចាន់ នី* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩០ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

៧ — ទណ្ឌិតឈ្មោះ *ប៉ាន់ ខុម* ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩០ របស់តុលាការប្រជាជនខេត្តកំពង់ធំ ។

*មាត្រា ២.* — ការលើកលែងទោសអោយទណ្ឌិតដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ

Downloaded from http://www.khmerlaws.com

សាមញ្ញ ដូចមានរាយឈ្មោះក្នុងមាត្រា ១ ពុំមានអានុភាពធ្វើអោយប៉ះពាល់ដល់ការសំរេចពី សំណាក់រដ្ឋប្បវេណីឡើយ ។

*មាត្រា ៣.* – ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តក្រឹត្យនេះ ។

*ធ្វើនៅភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩០*

ជ.ក្រុមប្រឹក្សារដ្ឋ

ប្រធាន

ហត្ថលេខា និង ត្រា

ហេង សំរិន

Downloaded from http://www.khmerlaws.com

# - ក្រុមប្រឹក្សារដ្ឋមន្ត្រី

## *អនុក្រឹត្យ*

*ភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩០*

## អនុក្រឹត្យ លេខ ៣៤ អ.ន.ក្រ

## ស្តីពីការរំសាយ បង្កើត និង ប្តូរឈ្មោះនាយកដ្ឋានមួយចំនួន ចំណុះក្រសួងការបរទេស

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញក្រឹត្យ-ច្បាប់លេខ ០៧ ក្រ ច ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៨២ ស្តីពីសមត្ថកិច្ច និងនីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ជា

— បានឃើញសេចក្តីសំរេចលេខ ៩១-៩០ គប ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩០ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា

— តាមសំណើរបស់សមមិត្តរដ្ឋមន្ត្រីក្រសួងការបរទេស

## សំរេច

*មាត្រា ១.* — រំសាយបង្កើត និង ប្តូរឈ្មោះនាយកដ្ឋានមួយចំនួន ចំណុះក្រសួងការបរទេស ដែលមានឈ្មោះដូចខាងក្រោម ៖

*ក — រំសាយនាយកដ្ឋានចំនួន ២ :*

— នាយកដ្ឋានសរុប

— នាយកដ្ឋានជំនួយការអង្គទូត

*ខ — បង្កើតនាយកដ្ឋានចំនួន ២ :*

— នាយកដ្ឋានសហប្រតិបត្តិការ និង វប្បធម៌ជាមួយបរទេស

— នាយកដ្ឋានឯកសារ

Downloaded from http://www.khmerlaws.com

*គ – ប្តូរឈ្មោះនាយកដ្ឋានចំនួន ៣ មាន :*

— នាយកដ្ឋានសូវៀត អឺរ៉ុបខាងកើត មកជានាយកដ្ឋានអឺរ៉ុប

— នាយកដ្ឋានអាមេរិកអឺរ៉ុបខាងលិច មកជា នាយកដ្ឋានអាមេរិក

— នាយកដ្ឋានអន្តរជាតិ មកជា នាយកដ្ឋានអង្គការសហប្រជាជាតិ សន្និសីទ អន្តរជាតិ និង អង្គការអន្តរជាតិ

*មាត្រា ២ —* តួនាទីភារកិច្ច និង របចនាសម្ព័ន្ធចាត់តាំងរបស់បណ្តានាយកដ្ឋានដូចបានបញ្ជាក់ខាងលើ អាស្រ័យដោយសេចក្តីរដ្ឋមន្ត្រីក្រសួងការបរទេសជាអ្នករៀបចំកំណត់សំរេច ។

ចំពោះក្របខ័ណ្ឌដាក់ស្តែងតាមនាយកដ្ឋាន អាស្រ័យដោយរដ្ឋមន្ត្រីក្រសួងការបរទេសពិគ្រោះដាក់ស្តែងជាមួយក្រសួងផែនការ ។

*មាត្រា ៣ —* បណ្តានាយកដ្ឋាននិមួយ ៗ ត្រូវមានប្រធានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួនជំនួយការ ។

*មាត្រា ៤ —* ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រសួងការបរទេស ក្រសួងផែនការ និង បណ្តាស្ថាប័នដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ចា ស៊ុង

Downloaded from http://www.khmerlaws.com

## ២- សេចក្ដីសំរេច

*ភ្នំពេញ, ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ១៩៩០*

# សេចក្ដីសំរេច លេខ ១៧៣ សសរ
## ស្ដីពីការប្រើប្រាស់អត្តសញ្ញាណប័ណ្ណពលរដ្ឋ
## ជំនួសលិខិតធ្វើដំណើរ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

*ប្រការ ១:* ពលរដ្ឋគ្រប់រូបចាប់ពីអាយុ ១៦ ឆ្នាំឡើង មានសិទ្ធប្រើប្រាស់អត្តសញ្ញាណប័ណ្ណពលរដ្ឋ ដើម្បីជាឯកសារសំគាល់ខ្លួន និងដើម្បីធ្វើដំណើរទៅមកក្នុងទូទាំងប្រទេស ដោយមិនចាំបាច់ប្រើប្រាស់លិខិតធ្វើដំណើរ លើកលែងតែទៅតំបន់ហាមឃាត់ ដែលត្រូវមានសេចក្ដីកំណត់ដោយឡែក ។

*ប្រការ ២ :* រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចចេញសេចក្ដីប្រកាស ដើម្បីណែនាំអនុវត្តជាក់ស្ដែងអោយមានប្រសិទ្ធភាពនូវសេចក្ដីសំរេចនេះ ។

*ប្រការ ៣ :* លិខិតបទដ្ឋាន និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

*ប្រការ ៤ :* រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន និងគណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និងត្រា

ជា សុទ្ធ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩១*

# សេចក្តីសំរេច លេខ ១៨០ សសរ

## ស្តីពីការផ្ទេរភារកិច្ចគ្រប់គ្រងបេឡាថវិការដ្ឋ ពីធនាគារជាតិមកក្រសួងហិរញ្ញវត្ថុ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

— បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

— បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— ផ្អែកតាមអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ

— តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ

## សំរេច

*ប្រការ ១* : ភារកិច្ចគ្រប់គ្រងបេឡាថវិការដ្ឋ ត្រូវបានផ្ទេរពីធនាគារជាតិមកអោយក្រសួងហិរញ្ញវត្ថុ និងបង្កើតប្រព័ន្ធរតនាគារជាតិចំណុះក្រសួងហិរញ្ញវត្ថុ ដូចបានកំណត់ក្នុងអនុក្រឹត្យលេខ ២៤ អនក្រ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងហិរញ្ញវត្ថុ ។

*ប្រការ ២* : ភារកិច្ច និង សិទ្ធអំណាចសំខាន់ ៗ របស់រតនាគារជាតិរួមមាន,

១ — គ្រប់គ្រងបេឡាថវិការដ្ឋ ប្រាក់បញ្ញើរបស់អង្គភាពគ្រោងទូទាត់ និង អង្គភាពសេដ្ឋកិច្ចផ្សេង ៗ អនុវត្តប្រមូលផ្តុំប្រភពចំណូលរបស់ថវិការដ្ឋ ចំណាយថវិកាអោយបណ្តាក្រសួង ខេត្ត ក្រុង និង អង្គភាពសេដ្ឋកិច្ចផ្សេង ៗ ទៀតតាមបញ្ជាចំណាយរបស់ក្រសួងហិរញ្ញវត្ថុ ។

២ — ធ្វើនិយ័តភាពសាច់ប្រាក់ក្នុងប្រព័ន្ធរតនាគារ ។

៣ — ធ្វើទំនាក់ទំនងផ្ទាល់ជាមួយអតិថិជន អំពីចំណូល-ចំណាយជាសាច់ប្រាក់ ឬផ្ទេរភារៈចំណាយរបស់អង្គភាពរដ្ឋបាលបុព្វហេតុ និងអង្គភាពសេដ្ឋកិច្ចផ្សេង ៗ ទៀត ។

៤ — ចាត់តាំងបោះផ្សាយឆ្នោតជាតិ និង ឥណទានរដ្ឋដូចជា : ប័ណ្ណស្នេហាជាតិមាតុភូមិ ប័ណ្ណឱ្យប្រាក់មានរយៈកាលកំណត់ . . . ។ ល ។

៥ — ចាត់តាំងបញ្ជីការគ្រប់គ្រងគណនេយ្យ ស្ថិតិ របាយការណ៍ចំណូល-ចំណាយ ថវិកា

Downloaded from http://www.khmerlaws.com

រដ្ឋ ប្រាក់បញ្ញើរបស់រតនាគារ និងទុនហិរញ្ញវត្ថុផ្សេងៗទៀតដែលផ្ញើនៅធនាគារជាតិដូចជា រូបិយប័ណ្ណបរទេសនិង បណ្ដាវត្ថុមានតម្លៃដែលរដ្ឋរឹបអូស ហើយដែលផ្ញើទុកនៅធនាគារជាតិរង់ចាំការដោះស្រាយ ។ល។

*ប្រការ ៣* : រតនាគារជាតិ មានសិទ្ធិបើកគណនីនៅធនាគារជាតិ ហើយនិងអនុវត្តតាមរបបរដ្ឋកំណត់អំពីការទូទាត់ ការគ្រប់គ្រងសាច់ប្រាក់ ។ ក្នុងពេលដែលបេឡាសាច់ប្រាក់មានច្រើននោះ រតនាគារជាតិត្រូវយកទៅផ្ញើនៅឯធនាគារជាតិ ។ ក្នុងករណីចាំបាច់ធនាគារជាតិ និង រតនាគារជាតិអាចខ្ចីប្រាក់ពីគ្នាទៅវិញទៅមកបាន ។

*ប្រការ ៤* : ប្រព័ន្ធរតនាគារជាតិ ត្រូវបានចាត់តាំងជាខ្សែបណ្ដោយពីមជ្ឈិមរហូតដល់មូលដ្ឋានខេត្ត ក្រុង :

- នៅមជ្ឈិម : មានរតនាគារជាតិ
- នៅតាមខេត្ត ក្រុង : មានរតនាគារ
- នៅទីកន្លែងឆ្ងាយដាច់ស្រយាល មានការលំបាកខាងផ្លូវគមនាគមន៍ តែមានប្រភពចំណូលច្រើន ត្រូវបានបង្កើតជាក្រុមប្រតិបត្តិការ រតនាគារស្ថិតក្រោមឱវាទរតនាគារ ។

*ប្រការ ៥* : ការចំណាយរបស់ប្រព័ន្ធរតនាគារជាតិ គឺអាស្រ័យដោយថវិកាមជ្ឈិមបើកផ្ដល់ ហើយប្រព័ន្ធរតនាគារជាតិត្រូវមានរបបបង្វិលបេឡាផ្ទេរផ្ទាន់ និងបេឡាសមូហភាព ។ល។ ដែលត្រូវកំណត់ណែនាំដោយក្រសួងហិរញ្ញវត្ថុ ។

*ប្រការ ៦* : ធនាគារជាតិនៃប្រជាជនកម្ពុជា ត្រូវផ្ទេរភារកិច្ចការងារបច្ចេកទេស មធ្យោបាយសម្ភារៈជាមូលដ្ឋាន និងក្របខ័ណ្ឌកម្មាភិបាល បុគ្គលិក ដែលកំពុងគ្រប់គ្រងបេឡាថវិការដ្ឋអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងហិរញ្ញវត្ថុ ។

*ប្រការ ៧* : ការអនុវត្តការកិច្ចការងាររបស់រតនាគារជាតិ ត្រូវចាប់ដំណើរការពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩១ តទៅ ។

*ប្រការ ៨* : រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ប្រធានធនាគារជាតិនៃប្រជាជនកម្ពុជា និង បណ្ដាស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ជា សុទ

Downloaded from http://www.khmerlaws.com

*ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩០*

# សេចក្តីសំរេចលេខ ១៨១ សសរ

## ស្តីពីគោលការណ៍ស្តារលទ្ធភាពពលកម្មបណ្តុះបណ្តាលវិជ្ជាជីវៈ និងដោះស្រាយការងារជូនជនពិការ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

– បានឃើញរដ្ឋធម្មនុញ្ញ នៃរដ្ឋកម្ពុជា

– បានឃើញច្បាប់ ស្តីពីអង្គការចាត់តាំង និងសកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

– បានឃើញក្រឹត្យ-ច្បាប់លេខ ១៩ ក្រ.ច ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ-សង្គមកិច្ច

– បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីតួនាទីភារកិច្ចរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងយុទ្ធជនពិការ-សង្គមកិច្ច

– តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ-សង្គមកិច្ច

## សំរេច

*ប្រការ ១* : បណ្តាមុខសញ្ញាបំពាក់វេយ្យៈសិប្បនិម្មិត កែវភ្នែកនិម្មិត និងឧបករណ៍សំរួលរាងកាយត្រូវបានពិនិត្យផ្តល់ជូនចំពោះ កម្មាភិបាល បុគ្គលិក កម្មករ យោធា នគរបាល ប្រជាជន និងកុមារា កុមារី ដែលមានលក្ខណៈពិការភាព ដូចខាងក្រោម :

– កំបុតដៃ ឬ កំបុតជើង

– ខ្វាក់ភ្នែក

– ស្វិតដៃ ស្វិតជើង

*ប្រការ ២* : បណ្តាមុខសញ្ញាព្យាបាលដោយចលនា ត្រូវបានពិនិត្យផ្តល់ជូនចំពោះ កម្មាភិបាល បុគ្គលិក កម្មករ យោធា នគរបាល ប្រជាជន និង កុមារា កុមារី ដែលមានលក្ខណៈពិការភាព និងមានពិការដូចខាងក្រោម :

– ពិការកំបុតដៃ - ជើង

Downloaded from http://www.khmerlaws.com

- ពិការជើងខ្វិនពីកំណើត
- ពិការស្លាប់មួយចំហៀងខ្លួន
- ពិការស្លាប់មួយកំណាត់ខ្លួន
- ពិការសរសៃប្រសាទ
- ពិការខួរក្បាល
- ពិការខ្សោយសាច់ដុំ
- ជម្ងឺស្វិតដៃ - ជើង
- ជម្ងឺគ្រាំគ្រា
- ជម្ងឺសន្លាក់
- ជម្ងឺបាក់ ថ្លោះ គ្រេច
- ឈឺចង្កេះ ឈឺស្មា ឈឺក

*ប្រការ ៣* : បណ្តាមុខសញ្ញាដែលមានចែងក្នុងប្រការ ១ និង ២ ត្រូវបានមជ្ឈមណ្ឌល និងរោងជាងស្តារលទ្ធភាពពលកម្ម បង្កលក្ខណៈងាយស្រួលចូលធ្វើដៃ-ជើងសិប្បនិម្មិត ដាក់កែវភ្នែក សិប្បនិម្មិត និង បំពាក់ឧបករណ៍សំរួលរាងកាយតាមលក្ខណៈពិការភាព ឬ ផ្តល់លទ្ធភាពព្យាបាលដោយចលនាដោយឥតគិតថ្លៃ ។

*ប្រការ ៤* : បណ្តាជនពិការទាំងឡាយដែលទទួលបានការបំពាក់នូវសម្ភារៈស្តារលទ្ធភាពពលកម្ម រួចហើយ បានត្រូវមជ្ឈមណ្ឌល និងរោងជាងស្តារលទ្ធភាពពលកម្មទទួលយក :

- ជួសជុលកែច្នៃជូនឡើងវិញក្នុងករណីប្រើប្រាស់មានការខូចខាតដោយប្រការផ្សេង ៗ ។
- ធ្វើជាថ្មីបំពាក់ជូនវិញ ក្នុងករណីការខូចខាតនោះមានកំរិតកែច្នៃមិនបាន ។

*ប្រការ ៥* : ជនពិការទាំងឡាយ ដែលបានចូលសំរាកនៅតាមមជ្ឈមណ្ឌល និង រោងជាងស្តារលទ្ធភាពពលកម្ម ដើម្បីធ្វើដៃ - ជើងសិប្បនិម្មិត ឬ ព្យាបាលដោយចលនា ត្រូវបានរដ្ឋជួយដោះស្រាយរបបហូបចុកប្រចាំថ្ងៃ ដូចជាអ្នកជម្ងឺដែលកំពុងសំរាកព្យាបាលនៅតាមមន្ទីរពេទ្យនានាដែរ ។

*ប្រការ ៦* : ក្រសួងយុទ្ធជនពិការ-សង្គមកិច្ច ក្រោយទទួលជនពិការដែលផ្ទេរមកពីក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ហើយបន្ទាប់ពីបានសំរួលរាងកាយជូនរួច

Downloaded from http://www.khmerlaws.com

ត្រូវទំនាក់ទំនង និងស្រាវជ្រាវជាមួយបណ្តាអង្គភាពរដ្ឋ ឯកជន រៀបចំការងារជូនអោយបានសមស្របតាមកំរិតប្រភេទពិការនីមួយ ៗ ដោយយោលលើលទ្ធភាព សមត្ថភាព និងទេពកោសល្យរបស់ជនពិការម្នាក់ ៗ ។

*ប្រការ ៧* : បណ្តាអង្គភាពរដ្ឋ មូលដ្ឋានផលិតកម្មរដ្ឋ រដ្ឋចំរុះឯកជន និងឯកជន ត្រូវទទួលយកជនពិការមកបំរើការងារក្នុងអង្គភាពមូលដ្ឋានខ្លួន តាមអត្រាមួយសមស្របនៃកំរិតកំហោត់ក្របខ័ណ្ឌ ។

*ប្រការ ៨* : បណ្តាសាលាចំណេះទូទៅ និងសាលាបណ្តុះបណ្តាលមុខវិជ្ជាជីវៈឯកទេស និងមុខជំនាញត្រូវទទួលជនពិការអោយចូលរៀនតាមលទ្ធភាព និងសមត្ថភាពរបស់គេ ។

*ប្រការ ៩* : ក្រសួងយុទ្ធជនពិការ - សង្គមកិច្ច មានភារកិច្ចរៀបចំបង្កើតរោងជាងបណ្តុះបណ្តាវិជ្ជាជីវៈ និងសិប្បកម្ម អាជីវកម្ម ដើម្បីដោះស្រាយការងារ សំដៅបង្កើនជីវភាពរស់នៅអោយជនពិការមានស្ថេរភាព ។

– មូលដ្ឋានសិប្បកម្ម អាជីវកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មនៃជនពិការផ្ទាល់ ត្រូវបានរដ្ឋផ្តល់អាទិភាពក្នុងការផ្គត់ផ្គង់ទុនវត្ថុធាតុដើម និងអនុគ្រោះពន្ធដារ វិភាគទានផ្សេង ៗ ក្នុងករណីដែលរដ្ឋជាអ្នកគ្រប់គ្រង ។

– ធនាគារជាតិត្រូវផ្តល់អាទិភាពក្នុងការអោយខ្ចីទុន ដើម្បីយកមកបំរើការងារដោយយកអត្រាការប្រាក់យ៉ាងទាបបំផុត ។

*ប្រការ ១០* : ក្រសួងយុទ្ធជនពិការ - សង្គមកិច្ច ត្រូវចេញប្រកាសណែនាំអនុវត្ត និងរៀបចំរចនាសម្ព័ន្ធចាត់តាំងការងារស្តារលទ្ធភាពពលកម្មពីមជ្ឈិមដល់មូលដ្ឋាន ។

– ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការប្រជាជនខេត្ត - ក្រុង ត្រូវយកចិត្តទុកដាក់លើកទឹកចិត្តដល់ជនពិការអោយធ្វើដើងសិប្បនិម្មិតបានគ្រប់ ៗ គ្នា ។

– ក្រសួងហិរញ្ញវត្ថុ ត្រូវកំណត់ឥណទានចាំបាច់សំរាប់ធានាការអនុវត្តជាក់ស្តែង ។

– ធនាគារជាតិនៃប្រជាជនកម្ពុជា ត្រូវអនុវត្តតាមរបបប្រាក់ចំណោយឧបត្ថម្ភចំពោះមុខសញ្ញា និងធានាការបើកផ្តល់ជូនបានទៀងទាត់ ។

– ក្រសួងអប់រំ ត្រូវកំណត់លក្ខខណ្ឌទទួលជនពិការពីក្រសួងយុទ្ធជនពិការ - សង្គមកិច្ច មកបំប៉នវប្បធម៌ និងបណ្តុះបណ្តាលមុខវិជ្ជាជីវៈ ។

Downloaded from http://www.khmerlaws.com

*ប្រការ ១១* : រាល់គោលការណ៍ពីមុនដែលផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

*ប្រការ ១២* : រដ្ឋមន្ត្រីទទួលបន្ទុកខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងការពារប្រទេស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ប្រធានធនាគារជាតិនៃប្រជាជនកម្ពុជា គណៈកម្មាធិការប្រជាជនខេត្ត - ក្រុង និង គ្រប់ផ្នែកដែលមានការពាក់ព័ន្ធមានភារកិច្ចអនុវត្តអោយមានប្រសិទ្ធភាព នូវសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ម៉ុ ៧០

Downloaded from http://www.khmerlaws.com

*ភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩០*

# សេចក្ដីសំរេចលេខ ១៨៤ សសរ

## ស្ដីពីរបបសោធននិវត្តន៍និងសោធនបាត់បង់សមត្ថភាព ពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

## ក្រុមប្រឹក្សារដ្ឋមន្ត្រី

បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា

— បានឃើញច្បាប់ស្ដីពីអង្គការចាត់តាំង និង សកម្មភាពរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ០៣ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

— បានឃើញក្រឹត្យ-ច្បាប់លេខ ១៩ ក្រ.ច ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ស្ដីពីការបង្កើតទីស្ដីការរដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ - សង្គមកិច្ច

— បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីតួនាទី ភារកិច្ច រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងយុទ្ធជនពិការ សង្គមកិច្ច

— បានឃើញសេចក្ដីសំរេចលេខ ១៥០ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបសោធននិវត្តន៍ និង សោធនបាត់បង់សមត្ថភាពពលកម្ម ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

— បានឃើញសេចក្ដីសំរេចលេខ ២៤៥ សសរ ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម

— តាមសំណើរដ្ឋមន្ត្រីក្រសួងយុទ្ធជនពិការ - សង្គមកិច្ច

## សំរេច

### I *របបសោធននិវត្តន៍*

*ប្រការ ១* : កម្មាភិបាល បុគ្គលិក កម្មកររដ្ឋទាំង ២ ភេទ អាចទទួលរបបសោធននិវត្តបាន លុះត្រាបំពេញលក្ខខណ្ឌដូចតទៅ ៖

— មានអាយុយ៉ាងតិច ៥៥ ឆ្នាំ និង រយៈពេលបំពេញការងារយ៉ាងតិច ២៥ ឆ្នាំ រហូតដល់ថ្ងៃចូលនិវត្តន៍ចំពោះបុរស ។

Downloaded from http://www.khmerlaws.com

— មានអាយុយ៉ាងតិច ៥០ ឆ្នាំ និងរយៈពេលបំពេញការងារយ៉ាងតិច ២០ ឆ្នាំ រហូតដល់ថ្ងៃចូលនិវត្តន៍ចំពោះនារី ។

រយៈពេលបំពេញការងារ ២៥ ឆ្នាំ និង ២០ ឆ្នាំខាងលើ ត្រូវមានរយៈពេលបំពេញការងារយ៉ាងតិច ៥ ឆ្នាំ ក្នុងរបបរដ្ឋកម្ពុជា ទើបអាចទទួលប្រាក់សោធននិវត្តន៍អប្បបរិមាបាន ។

*ប្រការ ២* : កម្មាភិបាល បុគ្គលិក កម្មកររដ្ឋដែលធ្វើការងារធ្ងន់ៗ ការងារពិបាក ការងារប៉ះពាល់សុខភាព ហើយបានអនុវត្តការងាររបស់ខ្លួនជាប់រហូត ក្នុងរយៈពេលយ៉ាងតិច ១២ ឆ្នាំ ចំពោះបុរស និង ១០ ឆ្នាំចំពោះនារី ការកំណត់អាយុ និង រយៈពេលបំពេញការងារក្នុងប្រការ ១ ត្រូវបន្ថយចំនួន ៥ ឆ្នាំ ។

ប្រាក់សោធននិវត្តន៍របស់សាមីខ្លួនម្នាក់ៗត្រូវបូកនឹងប្រាក់បន្ថែមចំនួន ១៥ ភាគរយនៃបៀវត្សថែមទៀត ។

*ប្រការ ៣* : កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ដើម្បីចូលនិវត្តន៍ហើយ តែដោយសារការចាំបាច់របស់ក្រសួង និងដោយសុខភាពរបស់សាមីខ្លួនអាចធានាការងារបានផង ដោយសាមីខ្លួនយល់ព្រមផង ក្រសួងគ្រប់គ្រងអាចសំរេច ឬ ស្នើសុំទៅថ្នាក់គ្រប់គ្រង មានសមត្ថកិច្ច អោយបន្តការងារមួយរយៈពេលទៀត ។ ក្នុងករណីនេះគេនៅមានសិទ្ធិពេញលេញដូចកម្មាភិបាល បុគ្គលិក កម្មកររដ្ឋដដែល ។

ចំពោះថេរវេលានៃកិច្ចការ ត្រូវកំណត់អោយបានសមស្របទៅតាមស្ថានភាព សុខភាពរបស់សាមីខ្លួន ។

*ប្រការ ៤* : ប្រាក់សោធននិវត្តន៍អប្បបរិមាកំណត់ ៥០ ភាគរយនៃប្រាក់បៀវត្ស ។

— ប្រាក់សោធននិវត្តន៍អតិបរិមាកំណត់ ៨០ ភាគរយនៃប្រាក់បៀវត្ស ។

*ប្រការ ៥* : កម្មាភិបាលតស៊ូបដិវត្តដែលបានបំពេញសកម្មភាពពីមុនឆ្នាំ ១៩៥៥ រហូតដល់ថ្ងៃចូលនិវត្តន៍ត្រូវទទួលប្រាក់សោធននិវត្តន៍អតិបរិមា បូកនឹងប្រាក់បន្ថែមអាទិភាពចំនួន ២០ ភាគរយនៃបៀវត្សបន្ថែមទៀត ។

ចំពោះកម្មាភិបាលដែលបានតស៊ូបដិវត្តចាប់ពីឆ្នាំ ១៩៥៥ និងបន្តបន្ទាប់មកទៀត រហូតដល់ថ្ងៃចូលនិវត្តន៍ ត្រូវទទួលប្រាក់សោធននិវត្តន៍អតិបរិមា បូកនឹងប្រាក់បន្ថែមអាទិភាពចំនួន ១៥ ភាគរយនៃបៀវត្សថែមទៀត ។

*ប្រការ ៦* : និវត្តជនដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ១ ការកំណត់ប្រាក់សោធននិវត្តន៍ ត្រូវគិតដូចខាងក្រោមនេះ ៖

Downloaded from http://www.khmerlaws.com

— ប្រាក់សោធននិវត្តន៍អប្បបរិមា មិនត្រូវតិចជាងបៀវត្សអប្បបរិមាឡើង ។ ក្នុងករណីតិចជាង ត្រូវតិតតម្លើងអោយស្មើនឹងបៀវត្សអប្បបរិមា ។

— ចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងារក្រោមរបបរដ្ឋកម្ពុជា អត្រាបន្ថែមលើប្រាក់សោធននិវត្តន៍កំណត់ ២ ភាគរយក្នុង ១ ឆ្នាំ នៃបៀវត្សរបស់សាមីខ្លួន ។ ប៉ុន្តែប្រាក់សោធននិវត្តន៍នេះ មិនត្រូវលើសកំរិតអតិបរិមាដែលបានកំណត់ក្នុងប្រការ ៤ ខាងលើឡើយ ។

— ប្រាក់សោធននិវត្តន៍ប្រចាំខែនីមួយៗ ត្រូវគិតទាំងប្រាក់បំណាច់តំបន់ដែលសាមីខ្លួនរស់នៅផង " ប្រសិនបើមាន " ។

*ប្រការ ៧* : ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំជីវភាពថ្មីនៅពេលចូលនិវត្តន៍ រដ្ឋនឹង ឧបត្ថម្ភបន្ថែមដល់និវត្តជន នូវទឹកប្រាក់ស្មើនឹងបៀវត្សសរុបពី ៥ ខែទៅ ៨ ខែ ។

— នៅពេលនិវត្តជនមានជម្ងឺ ឬ ស្លាប់ រដ្ឋជួយផ្គត់ផ្គង់និងឧបត្ថម្ភប្រាក់ធានារ៉ាប់រងសង្គមដូចមានចែងក្នុងសេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២៥៨ សសរ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ស្តីពីរបបគោលនយោបាយធានារ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ។

— ចំពោះកម្មាភិបាលដឹកនាំដែលមានរបបពេលកំពុងធ្វើការផ្ទាជា : លេខាធិការផ្ទាល់ កងការពារ អ្នកបំរើ អ្នកបើកបរមិនបានទៀតឡើយ ។

*ប្រការ ៨* : និវត្តជនដែលគ្មានទីពឹង ហើយគ្មានលទ្ធភាពធ្វើពលកម្ម ឬ ជួបការលំបាក ដោយពុំអាចដោះស្រាយជីវភាពផ្ទាល់ខ្លួនបាន គឺរដ្ឋអំណាច អង្គការមហាជន មូលដ្ឋាន ត្រូវ :

— បំផុសប្រជាជន មហាជន រួមចំណែកជួយចិញ្ចឹមបីបាច់ ។

ក្នុងករណីខាងលើមិនអាចដោះស្រាយបានទេ ត្រូវបានរដ្ឋទទួលចិញ្ចឹមក្នុងមជ្ឈមណ្ឌលសង្គ្រោះ ។

*ប្រការ ៩* : កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១ តែមានរយៈពេលបំពេញការងារក្នុងរបបរដ្ឋកម្ពុជាតិចជាង ៥ ឆ្នាំ រដ្ឋមិនផ្តល់ប្រាក់សោធននិវត្តន៍ឡើយ ក្នុងករណីនេះរដ្ឋផ្តល់ប្រាក់ឧបត្ថម្ភម្តងគត់ ស្មើនឹងបៀវត្សប្រចាំខែរបស់សាមីខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំរើការងារជូនបក្ស និង រដ្ឋ យ៉ាងតិចបំផុតស្មើនឹងបៀវត្សរបស់សាមីខ្លួន ២ ខែ ។

Downloaded from http://www.khmerlaws.com

## II – របបសោធនបាត់បង់សមត្ថភាពពលកម្ម

*ប្រការ ១០ :* កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលបាត់បង់សមត្ថភាពពលកម្មទាំងអស់ និងជាអចិន្ត្រៃយ៍ដោយជម្ងឺរ៉ាំរ៉ៃ គ្រោះថ្នាក់ផ្សេងៗ ឬ ដោយជរាភាព ហើយពុំមានលក្ខខណ្ឌដូចបានចែងក្នុងប្រការ ១ ដើម្បីចូលនិវត្តន៍ ត្រូវទទួលរបបសោធនបាត់បង់សមត្ថភាពពលកម្ម តែត្រូវមានរយៈពេលបំពេញការងារ ២០ ឆ្នាំ ចំពោះបុរស និង ១៥ ឆ្នាំ ចំពោះនារី ។

– រយៈពេលបំពេញការងារ ២០ ឆ្នាំ និង ១៥ ឆ្នាំខាងលើ ត្រូវមានរយៈពេលបំពេញការងារយ៉ាងតិច ៥ ឆ្នាំ ក្នុងរបបរដ្ឋកម្ពុជា ទើបបានទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មអប្បបរិមាបាន ។

– បើអ្នកទាំងនោះធ្វើការធ្ងន់ ការងារពិបាកនាំអោយប៉ះពាល់សុខភាព ហើយបានអនុវត្តការងាររបស់ខ្លួនជាប់ហេតុ ក្នុងរយៈពេលយ៉ាងតិច ១០ ឆ្នាំ ចំពោះបុរស និង ៨ ឆ្នាំ ចំពោះនារី រយៈពេលបំពេញការងារក្នុងចំណោមខាងលើ ត្រូវបន្ថយចំនួន ៥ ឆ្នាំ និង បន្ថែមប្រាក់ប៉ះពាល់សុខភាព ចំនួន ១០ ភាគរយនៃបៀវត្សសុទ្ធសាធថែមទៀត ។

– លក្ខខ័ណ្ឌខាងលើនេះ ពុំតម្រូវចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលបាត់បង់សមត្ថភាពពលកម្មដោយសារគ្រោះថ្នាក់ការងារ ឬ គ្រោះថ្នាក់ក្នុងពេលបំពេញបេសកកម្ម ហើយបណ្តាលអោយបាត់បង់សមត្ថភាពពលកម្មទាំងអស់ និង ជាអចិន្ត្រៃយ៍នោះទេ ។ ក្នុងករណីនេះ សាមីជនត្រូវទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មអតិបរិមា ។

ចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ដែលមានអាយុ ៥៥ ឆ្នាំ ចំពោះបុរស និង ៥០ ឆ្នាំ ចំពោះនារី មិនរយៈពេលបំពេញការងារតិចជាង ២៥ ឆ្នាំ និង ២០ ឆ្នាំ ទោះបីរយៈពេលបំពេញការងារក្នុងរបបរដ្ឋកម្ពុជា លើសពី ៥ ឆ្នាំក៏ដោយ ក៏ត្រូវទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្ម ។

*ប្រការ ១១ :* កម្មាភិបាល បុគ្គលិក កម្មកររដ្ឋទាំង ២ ភេទដែលបានប្រវត្តិស៊ូមុនឆ្នាំ ១៩៥៥ និងចាប់តាំងពីឆ្នាំ ១៩៥៥ នៅពេលគ្រប់លក្ខខ័ណ្ឌចូលបាត់បង់សមត្ថភាពពលកម្ម ត្រូវបានទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មអតិបរិមា ៦៥ ភាគរយនៃបៀវត្សសុទ្ធសាធ និងត្រូវបានផ្តល់ប្រាក់អាទិភាពចំនួន ១៥ ភាគរយ និង ១០ ភាគរយនៃបៀវត្សថែមទៀត ។

Downloaded from http://www.khmerlaws.com

*ប្រការ ១២* : ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មអប្បបរិមាកំណត់ ៤៥ ភាគរយនៃបៀវត្ស ។ ប៉ុន្តែបើទឹកប្រាក់ ៤៥ ភាគរយនៃបៀវត្សមានចំនួនទាបជាងទឹកប្រាក់ ៩០ ភាគរយនៃបៀវត្សអប្បបរិមា គេត្រូវតម្លើងអោយស្មើនឹងទឹកប្រាក់ខាងក្រោយនេះវិញ ។

– ចាប់ពីឆ្នាំទី ៦ នៃរយៈពេលបំពេញការងារក្រោមរបបរដ្ឋកម្ពុជា អត្រាបន្ថែមលើប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មកំណត់ ១៥ ភាគរយ រយៈពេលក្នុង ១ ឆ្នាំនៃបៀវត្សរបស់សាមីខ្លួន ។ ប៉ុន្តែប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មនេះ មិនត្រូវលើសកំរិតប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មអតិបរិមាដែលកំណត់ ៦៥ ភាគរយនៃបៀវត្សឡើយ ។

– ប្រាក់សោធនបាត់បង់សមត្ថភាពពលកម្ម ប្រចាំខែនីមួយ ៗ ត្រូវគិតទាំងប្រាក់បំណាច់តំបន់ដែលសាមីខ្លួនរស់នៅផង " ប្រសិនបើមាន " ។

*ប្រការ ១៣* : របបធានារ៉ាប់រងសង្គម និងរបបផ្សេង ៗ ចំពោះជនបាត់បង់សមត្ថភាពពលកម្ម គឺអនុវត្តដូចនិវត្តជនដែរ ។

– ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការរៀបចំជីវភាពថ្មី នៅពេលឈប់ធ្វើការហើយទៅទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្ម រដ្ឋនឹងបន្ថែមដល់សាមីខ្លួនម្តងគត់ នូវទឹកប្រាក់ស្មើនឹងបៀវត្សសរុបពី ៤ ខែ ទៅ ៦ ខែ ។

*ប្រការ ១៤* : ចំពោះអ្នកដែលមានរយៈពេលបំពេញការងារតិចជាង ៥ ឆ្នាំ ក្នុងរបបរដ្ឋកម្ពុជា និងអ្នកដែលពុំបានបំពេញលក្ខខណ្ឌក្នុងប្រការ ១០ ខាងលើ ពុំមានសិទ្ធិទទួលប្រាក់សោធនបាត់បង់សមត្ថភាពពលកម្មទៀងទាត់ជាអចិន្ត្រៃយ៍ឡើយ ។ ប៉ុន្តែត្រូវទទួលប្រាក់ឧបត្ថម្ភម្តងគត់ស្មើនឹងបៀវត្សប្រចាំខែរបស់ខ្លួន គុណនឹងចំនួនឆ្នាំដែលបានបំពេញការងារក្នុងរបបរដ្ឋកម្ពុជា ឬ យ៉ាងតិចបំផុតស្មើនឹងបៀវត្សរបស់សាមីខ្លួន ២ ខែ ។

*III – ការចាត់តាំងអនុវត្ត*

*ប្រការ ១៥* : ការចំណាយសំរាប់អនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ត្រូវទទួលបន្ទុកដោយថវិការដ្ឋ ។

*ប្រការ ១៦* : ដើម្បីអនុវត្តរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្មអោយមានប្រសិទ្ធភាពល្អ ក្រសួង មួយចំនួនខាងក្រោមត្រូវមានភារកិច្ចដូចតទៅ :

១ – គណៈចាត់តាំងមជ្ឈិម ពិនិត្យសំរេចអោយចូលនិវត្តន៍ ឬ បាត់បង់សមត្ថភាពពលកម្ម ចំពោះកម្មាភិបាលដែលនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម និងពិនិត្យទទួលស្គាល់រយៈពេលសកម្មភាពរបស់កម្មាភិបាលតស៊ូយូរឆ្នាំ ទៅតាមសំណើរបស់បណ្តាផ្នែក និងមូលដ្ឋាន ។

Downloaded from http://www.khmerlaws.com

២ – ក្រសួងយុទ្ធជនពិការ - សង្គមកិច្ច ត្រូវចេញប្រកាសណែនាំអនុវត្ត និងទំរង់បែបបទសំខាន់ៗ ដល់គ្រប់ក្រសួង មន្ទីរ ជុំវិញមជ្ឈិម និងខេត្ត-ក្រុង ។

– បង្កើតសៀវភៅបើកប្រាក់សោធននិវត្ត និងសោធនបាត់បង់សមត្ថភាពពលកម្មសំរាប់ប្រើប្រាស់អោយឯកភាពគ្នាទូទាំងប្រទេស ។

– ចេញសៀវភៅទាំងឡាយនោះ តាមសំណូមពររបស់ក្រសួង មន្ទីរ ជុំវិញមជ្ឈិម និងខេត្ត - ក្រុង ។

៣ – ក្រសួងសុខាភិបាលត្រូវចេញវិញ្ញាប័នប័ត្របញ្ជាក់អំពីសុខភាព និងការបាត់បង់សមត្ថភាពពលកម្មរបស់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋដោយសារសុខភាព ឬ គ្រោះថ្នាក់ផ្សេងៗ ។

- កំណត់ និងណែនាំអំពីការងារធ្ងន់ ការងារលំបាក ការងារប៉ះពាល់សុខភាពចំពោះកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ ។

– ណែនាំអំពីទំរង់បែបបទសំរាប់អោយនិវត្តជន និងជនបាត់បង់សមត្ថភាពពលកម្មចូលព្យាបាលនៅមន្ទីរពេទ្យ ការស្នាក់អាស្រ័យ ការហូបចុក និង ថ្នាំព្យាបាល ។

៤ – ក្រសួងហិរញ្ញវត្ថុត្រូវកំណត់ឥណទានចាំបាច់ សំរាប់ចំណាយលើរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពពលកម្ម ព្រមទាំងការចំណាយផ្សេងៗ ដែលមានការពាក់ព័ន្ធទៅក្នុងដំណើរការអនុវត្តនៃសេចក្ដីសំរេចនេះ ។

៥ – ខេត្ត-ក្រុង មានភារកិច្ចគ្រប់គ្រងមុខសញ្ញានិវត្តជន និងជនបាត់បង់សមត្ថភាពពលកម្ម ដោយគិតទាំងមុខសញ្ញាដែលមជ្ឈិម និង ខេត្ត-ក្រុង ផ្ទេរផ្ដល់អោយទៅរស់នៅតាមសំណើរបស់មុខសញ្ញា ។

*ប្រការ ១៧* : គ្រប់ក្រសួង មន្ទីរ ជុំវិញមជ្ឈិម គ្រប់ខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាល់គោលការណ៍ទាំងឡាយពីមុន ដែលផ្ទុយពីសេចក្ដីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី
អនុប្រធាន
ហត្ថលេខា និង ត្រា
ចា ស៊ុន

Downloaded from http://www.khmerlaws.com

ភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩០

# សេចក្តីណែនាំ លេខ ០៣ សណន

## ស្តីពីការកែសំរួលសេចក្តីណែនាំ លេខ ០៣ សណន
## ចុះថ្ងៃទី ១៣ មិថុនា ១៩៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុលោមតាមស្មារតីនៃសម័យប្រជុំពេញអង្គរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នាថ្ងៃទី ៥ , ៦ , ៧ ខែកក្កដា ឆ្នាំ១៩៩០ ស្តីពីការអនុញ្ញាតអោយបន្តទទួលពាក្យកាន់កាប់ដីរបស់ប្រជាកសិករ និង រួសរាន់វាស់វែង ប្រគល់លិខិតកាន់កាប់ជូនប្រជាជន ការអនុវត្តជំហានទី I យើងសំរេចទទួលពាក្យស្នើសុំកាន់កាប់ដីធ្លីទាំងប្រទេសបាន ៣.៥០០.០០០ ប្លង់ដី គឺ ប្រមាណ ៥០ ភាគរយប៉ុណ្ណោះ។

ដើម្បីអនុវត្តបន្ត និង ជំរុញអនុវត្ត ជំហានទី II គឺការធ្វើអង្កេតវាស់វែងផ្តល់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីជូនប្រជាជនទាន់ពេលវេលា និងស្របតាមលក្ខណៈបច្ចេកទេស សុរិយោដី ក្រុមប្រឹក្សារដ្ឋមន្ត្រី ធ្វើការណែនាំ និង កែសំរួលសមាសភាព គណៈកម្មការកណ្តាល "ថ្នាក់ស្រុក" និងអនុគណៈកម្មការអង្កេត វាស់វែងតាមឃុំនិមួយៗ ដែលមានចែងក្នុងសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ១៩៨៩ ដូចតទៅ :

គណៈកម្មាធិការប្រជាជនខេត្ត-ក្រុង ត្រូវចាត់តាំងគណៈកម្មការមូលដ្ឋានដែលមាន :

*គណៈ ម្មការកណ្តាល "ថ្នាក់ស្រុក"*

| | |
|---|---|
| - ប្រធានគណៈកម្មាធិការប្រជាជនស្រុក | ប្រធាន |
| - ប្រធានការិយាល័យ ភូមិបាល | អនុប្រធាន |
| - ប្រធានគណៈកម្មាធិការប្រជាជនគ្រប់ឃុំ | សមាជិក |

*អនុគណៈកម្មការអង្កេតវាស់វែងចុះអនុវត្តផ្ទាល់តាមឃុំ សង្កាត់និមួយ ៗ*

| | |
|---|---|
| - ប្រធានឃុំ សង្កាត់ | ប្រធាន |
| កម្មាភិបាលការិយាល័យសុរិយោដីខេត្ត-ក្រុង | អនុប្រធាន |
| - កម្មាភិបាលការិយាល័យកសិកម្មស្រុក ទំណ្ឋ | សមាជិក |
| - ប្រធានភូមិសាមី | - |
| - ចាស់ព្រឹទ្ធាចារ្យក្នុងភូមិ ១ នាក់ | - |

អនុគណៈកម្មការនេះ មានភារកិច្ចចុះធ្វើអង្កេតវាស់វែងជាក់ស្តែង បំពេញសំណុំលិខិតកំណត់ហេតុអោយបានច្បាស់លាស់ និង លើកសំណើជូនគណៈកម្មការកណ្តាលពិនិត្យ និង សំរេច ។

Downloaded from http://www.khmerlaws.com

ក្រសួងកសិកម្ម និង គណៈកម្មាធិការប្រជាជនគ្រប់ខេត្ត-ក្រុង ត្រូវសហការរៀបចំអោយបាន ជាបន្ទាន់ក្បាលម៉ាស៊ីនពីកត្រាការិយាល័យ សុរិយោដីខេត្ត ក្រុង និង ការិយាល័យភូមិបាលស្រុក ខ័ណ្ឌ ។

មន្ទីរនេះ ត្រូវសហការជំរុញអនុវត្ត ជំហាន ||| គឺការវាស់វែង ចុះបញ្ជី និង ចេញ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដីធ្លីទាន់សភាពការណ៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ្ធ

Downloaded from http://www.khmerlaws.com

## ៥– សេចក្តីកំណត់

ភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ១៩៩០

## សេចក្តីកំណត់ លេខ ០១ សកណ

### អំពីទង់ប្រឡងប្រណាំងស្នេហាជាតិ ការពារកសាងមាតុភូមិ ឆ្នាំ ១៩៩១-១៩៩៥

ក្នុងសភាពការណ៍វិវឌ្ឍន៍រីកចំរើនយ៉ាងខ្លាំងនៃមាតុភូមិកម្ពុជាក្នុងដំណាក់កាលថ្មី ដែលពោរពេញទៅដោយស្មារតីជ័យជំនះ និង ដើម្បីជំរុញចលនាប្រឡងប្រណាំងស្នេហាជាតិរបស់ប្រជាជន កងកម្លាំងប្រដាប់អាវុធ និង កម្មាភិបាល កម្មករ បុគ្គលិក នៅទូទាំងប្រទេស អោយមានសន្ទុះកាន់តែខ្លាំងក្លា សំរេចបាននូវស្នាដៃធំ ៗ ថ្មី ៗ ថែមទៀត ក្នុងភារកិច្ចវាយកំទេចខ្មាំងសត្រូវ ការពារមាតុភូមិរឹងមាំ និង កសាងប្រទេសជាតិអោយកាន់តែសម្បូរសប្បាយរុងរឿងឡើង។

ក្រុមប្រឹក្សារដ្ឋមន្ត្រីណែនាំគ្រប់ក្រសួង ស្ថាប័នជុំវិញមជ្ឈិម និង គ្រប់ខេត្ត-ក្រុង ដូចខាងក្រោមនេះ ៖

១ – ចំពោះទង់ប្រឡងប្រណាំងរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ប្រភេទទង់ចល័តដែលបានកំណត់ចែងក្នុងសេចក្តីកំណត់លេខ ០៣ សកណ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ដែលមានរយៈពេលវែង គឺនៅចុងឆ្នាំ ១៩៩០ នេះត្រូវបញ្ចប់ ។ ដូច្នេះគ្រប់ក្រសួង ស្ថាប័នជុំវិញមជ្ឈិម និង គ្រប់ខេត្ត-ក្រុង ដែលត្រូវបានក្រុមប្រឹក្សារដ្ឋមន្ត្រីប្រគល់ជូនទង់ចល័តក្រុមប្រឹក្សារដ្ឋមន្ត្រី សំរាប់បំផុសចលនាប្រឡងប្រណាំង ត្រូវអនុវត្តតាមសេចក្តីកំណត់ ដោយបូកសរុបស្នាដៃរបស់បណ្តាអង្គភាពដែលធ្លាប់បានទទួលទង់កន្លងមក ដើម្បីប្រគល់ជូនផ្តាច់ព្រ័ត្រដល់អង្គភាពណាដែលសំរេចបានស្នាដៃច្រើនផងជាងគេនាឱកាសបូកសរុបស្នាដៃឆ្នាំ ១៩៩០ នេះតែម្តង ដោយលើកសំណើសុំសេចក្តីសំរេចពីក្រុមប្រឹក្សារដ្ឋមន្ត្រី ។ ទន្ទឹមនោះ អាចពិនិត្យលើស្នាដៃជាក់ស្តែង ឆ្នើមពិសេសរបស់អង្គភាពដែលត្រូវបានទទួលទង់ចល័តក្រុមប្រឹក្សារដ្ឋមន្ត្រីផ្តាច់ ដើម្បីលើកសរសើរបន្ថែមជាគ្រឿងឥស្សរិយយសតាមកំរិតស្នាដៃ ។

២ – ការបែងចែកទង់ប្រឡងប្រណាំងសំរាប់ឆ្នាំ ១៩៩១-១៩៩៥ មានដូចខាងក្រោមនេះ

Downloaded from http://www.khmerlaws.com

ក – ចំពោះក្រសួងការពារប្រទេស និង ក្រសួងមហាផ្ទៃ ចំនួនទង់ចល័តក្រុមប្រឹក្សារដ្ឋមន្ត្រី ទង់ជ័យលាភីក្រុមប្រឹក្សារដ្ឋមន្ត្រី និង ទង់ជ័យលាភីថ្នាក់ក្រសួងនៅរក្សាទុកដូចមុនដដែល ។

ខ – ចំពោះគ្រប់ក្រសួង ស្ថាប័ន ជុំវិញមជ្ឈិម ក្រៅពីក្រសួងទាំងពីខាងលើ និងគ្រប់ខេត្ត-ក្រុង ក្រុមប្រឹក្សារដ្ឋមន្ត្រីអនុញ្ញាតអោយប្រើប្រាស់ទង់ចល័តរបស់ថ្នាក់ក្រសួង និង ខេត្ត-ក្រុង សំរាប់រយៈពេល ៥ ឆ្នាំ ១៩៩១ - ១៩៩៥ ជូនចំពោះបណ្ដាផែនប្រឡងប្រណាំងដែលចំណុះក្រសួង ខេត្ត-ក្រុងផ្ទាល់ តាមចំនួនផែនប្រឡងប្រណាំងដែលបានចាត់តាំង ។

គ – ចំពោះបណ្ដានាយកដ្ឋាន មន្ទីរ សហគ្រាស ក្រុមហ៊ុន ថ្នាក់ស្មើនាយកដ្ឋាន ដែលមានអង្គភាពក្រោមឱវាទច្រើន និង បណ្ដាខ័ណ្ឌ ស្រុក ក្រុមប្រឹក្សារដ្ឋមន្ត្រីអនុញ្ញាតអោយប្រើប្រាស់ទង់ជ័យលាភីប្រចាំឆ្នាំនីមួយ ៗ របស់ថ្នាក់ខ្លួន សំរាប់ជូនរង្វាន់ដល់អង្គភាពចំណុះដែលមានស្នាដៃឆ្នើមឈានមុខតាមផែននីមួយ ៗ ដែលបណ្ដាអង្គភាពថ្នាក់លើបានចាត់តាំងជាផែនប្រឡង-ប្រណាំង ។

ចំពោះរូបភាពទង់ប្រឡងប្រណាំង និង ទំហំ គឺរក្សាទុកដូចការកំណត់មុន ដោយគ្រាន់តែតម្រូវប្រាសាទកំពូលប្រាំអោយមានក្បាច់រចនាដូចប្រាសាទក្នុងទង់ជាតិប៉ុណ្ណោះ ។

ចំពោះប្រាក់រង្វាន់អមទង់ប្រឡងប្រណាំងសំរាប់ឆ្នាំ ១៩៩១ - ១៩៩៥ មានដូចខាងក្រោមនេះ :

ចំពោះទង់ចល័តក្រុមប្រឹក្សារដ្ឋមន្ត្រី រង្វាន់អមគិតស្មើជាប្រាក់ ២០.០០០ រៀល សំរាប់ឆ្នាំនីមួយ ៗ ។

ទង់ចល័តថ្នាក់ក្រសួង ស្ថាប័នជុំវិញមជ្ឈិម និង ខេត្ត-ក្រុង និង ទង់ជ័យលាភីរបស់ក្រសួងការពារប្រទេស និង ក្រសួងមហាផ្ទៃ រង្វាន់អមគិតស្មើជាប្រាក់ ១០.០០០ រៀល សំរាប់ឆ្នាំនីមួយ ៗ ។

ទង់ជ័យលាភីថ្នាក់នាយកដ្ឋាន មន្ទីរ សហគ្រាស ក្រុមហ៊ុនថ្នាក់ស្មើនាយកដ្ឋាន និង ខ័ណ្ឌ ស្រុក រង្វាន់អមគិតស្មើជាប្រាក់ ៦ ០០០ រៀល សំរាប់ឆ្នាំនីមួយ ៗ ។

ចំពោះការចំណាយធ្វើទង់ប្រឡងប្រណាំង និង រង្វាន់ភ្ជាប់ជាមួយទង់គ្រប់ប្រភេទសំរាប់ឆ្នាំនីមួយ ៗ គឺក្រសួង ស្ថាប័ន ជុំវិញមជ្ឈិម និង គ្រប់ខេត្ត-ក្រុង ត្រូវលើកគម្រោងស្នើក្រសួងហិរញ្ញវត្ថុពិនិត្យ សំរេច ។ ក្រសួងហិរញ្ញវត្ថុ ត្រូវធ្វើការណែនាំជាក់ស្ដែងអំពីរបៀបបទដល់គ្រប់ក្រសួង ស្ថាប័ន ជុំវិញមជ្ឈិម និង គ្រប់ខេត្ត-ក្រុង ចំពោះខ្ទង់ចំណាយនេះ ។

Downloaded from http://www.khmerlaws.com

គ្រប់ក្រសួង ស្ថាប័ន ជុំវិញមជ្ឈិម និង គ្រប់ខេត្ត ក្រុង ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមការកំណត់នេះ ។

ជ. ក្រុមប្រឹក្សារដ្ឋមន្ត្រី

អនុប្រធាន

ហត្ថលេខា និង ត្រា

ជា សុទ

Downloaded from http://www.khmerlaws.com

# ពាក្យកែតម្រូវរដ្ឋកិច្ចលេខ ១២ ឆ្ន ១៩៩០

| លរ | លេខទំព័រ | លេខបន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|---|
| ១ | ក | ១៨ | និងសោន | និងសោធន |
| ២ | ៣០៨ | ១៧ | នោ | នៅ |
| ៣ | ៣០៨ | ១៨ | កំណៈត | កំណត់ |
| ៤ | ៣០៨ | ២៣ | ការលើ | ការលើក |
| ៥ | ៣១០ | ១៨ | ខេត្តកំពង់កំ | ខេត្តកំពង់ធំ |
| ៥ | ៣១០ | ២៤ | ខេត ៉ពង់ធំ | ខេត្តកំពង់ធំ |
| — | ៣១០ | ២៥ | ការលើ លែងទោស | ការលើកលែងទោស |
| ៦ | ៣១៦ | ១៥ | ប ង្កើត | បង្កើត |
| ៧ | ៣១៧ | ១៤ | សរេច | សំរេច |
| ៨ | ៣១៩ | ២៥ | ពិកាពើក្រសួង | ពីការពីក្រសួង |
| ៩ | ៣២៤ | ១ | បាតបង | បាត់បង់ |
| ១០ | ៣២៥ | ១៩ | ឧបត្ថម | ឧបត្ថម្ភ |

Downloaded from http://www.khmerlaws.com

សហគ្រាសសម្ព័ន្ធរោងពុម្ព
បោះពុម្ពនៅរោងពុម្ពសុខាភិបាល
លើកទី ១ ចំនួន ៩.០០០ ច្បាប់

Downloaded from http://www.khmerlaws.com